**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

<ins>**តុលាការកំពូល**</ins>

**អង្គនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១២៣

ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤

សាលដីកា

លេខ : ៣៨

ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | ជីវ កេង | ចៅក្រម |
| ៤- លោក | ប៉ែន សាវឿន | ចៅក្រម-របាយការណ៍ |
| ៥- លោក | សោម សិរីវឌ្ឍ | ចៅក្រម |

ក្រឡាបញ្ជី

អ្នកស្រី សុផុន សុមានីកា

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៦ "ជ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១២៣ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

<ins>*ពីបទ*</ins> : រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីឆ្នាំ២០០០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ប៉ាង ហោ (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្វា ឃុំបឹងក្រាញ់ ស្រុកសំរោង ខេត្តតាកែវ មុខរបរពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៤៤C ផ្លូវ៣៥៦ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះប៉ាង សេង "ស" ម្តាយឈ្មោះសៅ អាយ "ស" ប្រពន្ធឈ្មោះសុខ សំណាង មានកូន០៣នាក់ ។ ទោសពីមុនគ្មាន ។

-មេធាវី : លោកស្រី លៀន ចិន្តា

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះតៃ យីវហេង (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៥E₀ ផ្លូវ៣១០ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

-មេធាវី : គ្មាន

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះតែ យីវហេង បញ្ជាក់ថា ខ្លួនប្តឹងពីឈ្មោះប៉ាង ហោ ហៅ ឡោ ឈុនហោ ដោយហេតុថា នៅចុងឆ្នាំ១៩៩៨ និងដើមឆ្នាំ១៩៩៩ ខ្លួនបានបើកក្រុមហ៊ុនជាមួយឈ្មោះនេះ ដែលមានឈ្មោះក្រុមហ៊ុន គី វិន្តវិន្តច្រេីង ។

បន្ទាប់ពីមានច្បាប់អនុញ្ញាតិធ្វើអាជីវកម្មរួចមក ក្រុមហ៊ុនបានដំណើរការដល់ឆ្នាំ២០០០ ទើបខ្លួនសុំឱ្យឈ្មោះនេះ ទូទាត់បញ្ជីលុយកាក់ម្តង តែឈ្មោះនេះបញ្ជាក់ថា ពុំមានប្រាក់សល់នៅក្នុងក្រុមហ៊ុនទេ ។ លុះដល់ខ្លួនតាមដានសកម្មភាពឈ្មោះនេះយូរទៅ ទើបដឹងថា ការប្រើប្រាស់ឈ្មោះក្រុមហ៊ុនជាឈ្មោះគង់ណារិទ្ធ តែហត្ថលេខាជារបស់ឈ្មោះប៉ាង ហោទៅវិញ សបញ្ជាក់ឱ្យឃើញថា ឈ្មោះនេះបានក្លែងបន្លំឈ្មោះ និង ដើម្បីរំលោភលើលក្ខន្តិកៈក្រុមហ៊ុនទៅវិញ ជាហេតុធ្វើឱ្យខ្លួនខាតបង់ប្រាក់ជាច្រើន ។

-បានឃើញដីកាលើកលែងចោទប្រកាន់លេខ៨០៦៨ត.ព្រ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេច :

+លើកលែងចោទប្រកាន់លើឈ្មោះប៉ាង ហោ ហៅ តាម៉ាប់ ភេទប្រុស អាយុ៥៦ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិស្វា ឃុំបឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះប៉ាង សេង "ស្លាប់" ម្តាយឈ្មោះសៅ អាយ "ស្លាប់" ប្រពន្ធឈ្មោះសុខ សំណាង មានកូន០៣នាក់ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ២៤៤C ផ្លូវ៣៥៦ សង្កាត់ទួលស្វាយព្រៃII ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ទោសពីមុនគ្មាន ពីបទរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីឆ្នាំ២០០០ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះតែ យីវហេង ប្តឹងមិនសុខចិត្តពីដីកាលើកលែងចោទប្រកាន់លេខ៨០៦៨ត.ព្រ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់ចៅក្រមស៊ើប-អង្កេតតុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

+ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះតែ យីវហេង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

+តម្កល់ដីកាលើកលែងចោទប្រកាន់លេខ៨០៦៨ត.ព្រ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០"ជ"ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះតែ យីវហេង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសគតិច្បាប់ ។

២-តម្កល់ដីកាលើកលែងចោទប្រកាន់លេខ៨០៦៨ ត.ព្រ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះតៃ យីវហេង ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១០"ជ"ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៦"ជ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះតៃ យីវហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ១០"ជ" ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៧៤ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះតៃ យីវហេង ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១៦"ជ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះតៃ យីវហេង ។

-បានឃើញសារណាតប ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៥ របស់ឈ្មោះប៉ាង ហោ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

+តាមឯកសារដែលពាក់ព័ន្ធពុំឃើញមានភស្តុតាងណាដាក់បន្ទុកលើឈ្មោះ ប៉ាង ហោ ពីបទរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីឆ្នាំ២០០០ ទេ ។

+តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៦"ជ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះតែ យីវហេង នាពេលសវនាការថា : នៅឆ្នាំ១៩៩២ ខ្ញុំ តែ យីវហេង ,ប៉ាង ហោ,លឹម ស៊ីថា និង តាំង សំរេច បង្កើតក្រុមហ៊ុនឡោ ឈុនហោ លុះដល់ឆ្នាំ១៩៩៨ ឈ្មោះប៉ាង ហោ បបួលបិទក្រុមហ៊ុន ចាស់បង្កើតក្រុមហ៊ុនថ្មីឈ្មោះវីន្តវីន្តច្រីង ។ ឈ្មោះប៉ាង ហោ មាន ចេតនាទុច្ចរិត និង កិបកេងប្រាក់របស់ក្រុមហ៊ុន មិនឱ្យខ្ញុំដឹង គឺថាឈ្មោះនេះពុំមានធ្វើបញ្ជីឱ្យច្បាស់ លាស់ទេ ។ ឈ្មោះសុខ ហេង ជាមន្ត្រីពន្ធដារ ធ្លាប់ទៅបង់ពន្ធ និង ធ្លាប់ធ្វើគណនេយ្យ មានចុះឈ្មោះខ្ញុំ និង ប៉ាង ហោ ។ នៅឆ្នាំ២០០០ គេដេញខ្ញុំចេញ គេបានលាក់ឯកសារទាំងអស់ ខ្ញុំបានចុះការសែតប្រកាស ខ្ញុំបាទសុំយកលក្ខន្តិកៈមកមើល គេមិនឱ្យ លាក់ បាត់រហូត ។ លឹម ស៊ីថា កាន់បញ្ជី ប៉ាង ហោ កាន់លុយ ពេលចុងឆ្នាំមិនបានធ្វើបញ្ជីឱ្យដឹង ខ្ញុំធ្វើការស្រាវ ជ្រាវឃើញ ប៉ាង ហោ ក្លែងឈ្មោះគង់ ណារិទ្ធ ចំណែកលុយដំណើរការ គឺលុយក្រុមហ៊ុនចាស់ទាំងអស់ ។

+តើលោកត្រូវធ្វើយ៉ាងណាឱ្យតុលាការដឹងថា អ្នកធ្វើអាជីវកម្មលើវីន្តវីន្តច្រីង គឺមានឈ្មោះ ប៉ាង ហោ ក្លែង ?

+លោកត្រូវប្តឹងតាមតុលាការរដ្ឋប្បវេណីឱ្យគេជំរះបញ្ជីទិន្នន័យ គឺរកឱ្យឃើញសិន បើប្តឹងមក តុលាការព្រហ្មទណ្ឌតែម្តង រកម៉េចឃើញ ។

+គេមានល្បិចក្លែងគិតទុកជាមុន ។ ស្រាវជ្រាវសាក្សីនៅសាលាដំបូងអាចរកឃើញនិយាយពី ក្រុមហ៊ុនគឺមានលក្ខន្តិកៈ ។

+ក្រុមហ៊ុនមានមនុស្សដំណើរការរហូតមក មានទទំនបន្តគ្នារហូត ។ ខ្ញុំអស់លុយរលីង បើខាងគេ ខាត គេមាននាំចូលឥវ៉ាន់ទាំងកុងតឺន័រ មានឡានជិះ មានផ្ទះល្វែង ។

+ផ្ទះដែលជួលហ្នឹងសុទ្ធតែគេស្គាល់មនុស្សទាំងអស់ ដំណើរការធ្វើអ្វីក៏ឈ្មោះប៉ាង ហោ ទាំងអស់។ ចម្លើយខ្ញុំជាការពិតមិនមានភរកុហក់អ្វីទេ ។

-បានស្តាប់ក្រឡាបញ្ជីអានសាវតាជាតិ និង សារណាតប របស់ជនជាប់ចោទឈ្មោះប៉ាង ហោ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រីលៀន ចិន្តា ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ ប៉ាង ហោ នាពេលសវនាការថា : តាមសារណារបស់លោកតែ យីវហេង ថា កូនក្តីរបស់នាងខ្ញុំរំលោភលើ សេចក្តីទុកចិត្ត ។ ការរកស៊ីចូលគ្នាទាំង០៤នាក់ ពុំមានលក្ខន្តិកៈអ្វីឡើយគឺ រកស៊ីតាមការស្រុះស្រួលគ្នាតែ ប៉ុណ្ណោះ ។

+ក្រុមហ៊ុនវីន្តវីន្តច្រីង មានតាំងសំរេចកាន់បញ្ជីនិង ប៉ាង ហោ កាន់លុយបើមិនត្រូវគ្នាក៏មិនធ្វើការ ជាមួយគ្នាបានដែរ ។

+ក្រុមហ៊ុនវីន្តវីន្តច្រីងនៅឆ្នាំ២០០០ អ្នកទាំងបួនក៏ឈប់រកស៊ីចូលគ្នា ហើយចែកលុយលើកទី១ បាន២.៦០០ដុល្លា និង ៥០០ដុល្លាទៀត ពីក្រុមហ៊ុនចាស់ និង ថ្មី ។

+គាត់មកធ្វើការឱ្យក្រុមហ៊ុនវីន្តវីន្តច្រីង រយៈពេលជាងមួយឆ្នាំហេតុអ្វីបានជាពុំដឹងថាអ្នកណាជា ប្រធានក្រុមហ៊ុន ?

+គាត់គ្មានឯកសារណាពាក់ព័ន្ធដើម្បីបញ្ជាក់ថា កូនក្តីនាងខ្ញុំត្រូវចោទពីបទក្លែងបានទេ ។ បើគាត់ប្តឹងគួរតែប្តឹងទាំងអស់គ្នា មិនមែនអាចប្តឹងតែកូនក្តីខ្ញុំឈ្មោះប៉ាង ហោ ម្នាក់ទេ ។

+គ្មានអ្នកណាម្នាក់ រឺ បុគ្គលិកក្នុងក្រុមហ៊ុនមកបញ្ជាក់ថា ប៉ាង ហោ មានគំនិតកិបកេងលុយរបស់ក្រុមហ៊ុនទេ ដោយសារការរកស៊ីខាត និង ក្រោយពីការចែកហ៊ុនគ្នា ពុំមានដើមទន់ទេ ។ សព្វថ្ងៃកូនក្តីខ្ញុំទៅលក់ខោ អាវ ជជុះនៅអូរស្មាច់ខេត្តបន្ទាយមានជ័យ ៕

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : ពុំមានមតិអ្វីបន្ថែមទៀតទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ,សារណារបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៧៤ ចុះថ្ងៃទី១៥ខែមិថុនា ឆ្នាំ២០០៤របស់ឈ្មោះតែ យីវហេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនៅក្នុងសារណា និង នៅពេលសវនាការនេះថាឈ្មោះប៉ាង ហោ មានចេតនាទុច្ចរិត និង កិបកេងប្រាក់របស់ក្រុមហ៊ុនមិនឱ្យលោកដឹងនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា : តាមចម្លើយរបស់ឈ្មោះតែ យីវហេង ឆ្លើយអះអាងទាំងនៅតុលាការថ្នាក់ក្រោម ក៏ដូចជាពេលសវនាការនេះដែរ ថាខ្លួនបានបើកក្រុមហ៊ុនវីន្តវីន្តច្រើងក្នុងខែមករា ឆ្នាំ១៩៩៩ ដោយខ្លួនមានភាគហ៊ុន៤០% និង ប៉ាង ហោ មាន៦០% ក្រុមហ៊ុនដំណើរការជាធម្មតារហូតដល់ខែសីហា ឆ្នាំ២០០០ ។ ចម្លើយនេះ បញ្ជាក់ឱ្យឃើញថា ចាប់តាំងពីចុះហត្ថលេខាបង្កើតក្រុមហ៊ុនមក មានរយៈពេលជាងមួយឆ្នាំពិតជាដឹងថា អ្នកណាជាប្រធានក្រុមហ៊ុនហើយ ព្រោះនៅក្នុងលក្ខន្តិកៈ គឺឈ្មោះគង់ ណារិទ្ធជាប្រធាន រីឯឈ្មោះប៉ាង ហោ ពុំមានឈ្មោះនៅក្នុងក្រុមហ៊ុនទេ ដូច្នេះជនជាប់ចោទពុំមានសិទ្ធិនៅក្នុងក្រុមហ៊ុនវីន្តវីន្តច្រើងឡើយ ។

-យល់ឃើញថា នៅក្នុងរឿងក្តីនេះពុំមានឯកសារណាបញ្ជាក់ថា ជនជាប់ចោទឈ្មោះប៉ាង ហោ បានរំលោភយកប្រាក់ក្រុមហ៊ុនទៅចាយវាយខុសគោលដៅ ដុយពីឆន្ទៈរបស់លោកតែ យីវហេង ទេ ។ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថា ឈ្មោះប៉ាង ហោ បានយកឈ្មោះក្រុមហ៊ុនវីន្តវីន្តច្រើង ទៅធ្វើពាណិជ្ជកម្មបន្តទៀតទេ ។ ម្យ៉ាងទៀតនៅឆ្នាំ២០០០ លោកតែ យីវហេង បានទទួលប្រាក់ទូទាត់ភាគហ៊ុន៣១០០

ដុល្លាអាមេរិករួចហើយ ដោយមានឈ្មោះតាំង សំរេច ដែលជាសមាជិកភាគហ៊ុន ចាស់ដែរ នោះក៏បាន បញ្ជាក់ថា ប្រាក់នេះជាប្រាក់ទូទាត់បញ្ជីដែរ និង មានការយល់ព្រមពីលោកតែ យីវហេង ផង ។

-យល់ឃើញថា ជនជាប់ចោទបានទទួលដីកាកោះឱ្យចូលខ្លួនរួចហើយ ប៉ុន្តែមិនបានចូលរួម នាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខជនជាប់ចោទ ប៉ុន្តែ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៦"ដ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

*វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងវិវាទ័ *[sic]* កំបាំងមុខជនជាប់ចោទ*

*ប៉ុន្តែចាត់ទុកជាចំពោះមុខ*

១-ទទួលបណ្តឹងសាទុក្ខលេខ៧៤ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះតែ យីវហេង ទុក ជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៦"ដ" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់សាលា- ឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ ។